# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ២ ចេញផ្សាយថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣

Issue 2 : 25 / 4 / 2023


## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

# គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០នាទី នៅសាលសន្និសីទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត





ឯកឧត្តម នុត សុខុម អនុប្រធាន គ.ជ.ប

តទៅទំព័រទី២

**មាតិកា៖** **ទំព័រ**


- គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ ........................១
- ប្រធាន គ.ជ.ប ទទួលជួបឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា..................................................៤
- គណបក្សនយោបាយ ចំនួន ១៣ បានដាក់ពាក្យស្នើសុំបង្កើតគណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយ...៦
- គ.ជ.ប រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន ...........៦
- ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស សម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ .......៨
- ការងារចាំបាច់ចំពោះមុខ គឺការធានាឱ្យបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ ជាពិសេសក្នុងដំណើរការបោះឆ្នោត ...៨
- សំណួរ-ចម្លើយ ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ...................................៩

តមកពីទំព័រទី១ គ.ជ.ប រៀបចំកិច្ចប្រជុំ ...

(គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ក្រោមអធិបតីភាព ឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ការប្ដឹងតវ៉ា និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។

មានប្រសាសន៍ក្នុងអង្គប្រជុំនោះ ឯកឧត្តម **នុត សុខុម** បានបញ្ជាក់ជូនថា តាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយចាប់ផ្ដើមពីថ្ងៃទី២៤ ខែមេសា រហូតដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ឯកឧត្តមអនុប្រធាន គ.ជ.ប បានបន្តថា ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវធ្វើនៅ គ.ជ.ប។ ប្រធានគណបក្សនយោ-បាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍-អក្សរពីប្រធានគណបក្សនយោបាយ ត្រូវចុះហត្ថលេខាលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

ឯកឧត្តម **នុត សុខុម** បានជម្រាបជូនដល់ភាគីពាក់ព័ន្ធអំពីនីតិវិធីនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះ-



**សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

ឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ អំពីភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន និងភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន។ ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទ សម្រាប់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុម-ប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទ រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរ។ ឯកឧត្តមបន្តថា គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ។

ចំពោះការប្ដឹងតវ៉ា និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះ-ឆ្នោត ឯកឧត្តម **នុត សុខុម** បានមានប្រសាសន៍ថា សាមីគណបក្សនយោបាយ ឬតំណាង អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចបដិសេធដោយ គ.ជ.ប លើបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន។ គណបក្សនយោបាយអាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី។

ឯកឧត្តម **នុត សុខុម** បានមានប្រសាសន៍ទៀតថា បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេលដែលពាក្យបណ្តឹងតវ៉ាត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរ គ.ជ.ប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត របស់គណបក្សនយោបាយទាំងនោះក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

មានចម្ងល់មួយចំនួនរបស់តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមក្នុងកិច្ចប្រជុំ ទាក់ទងនឹងការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការបញ្ជាក់ឈ្មោះបេក្ខជនជួបបញ្ហានៅមូលដ្ឋាន ការធ្វើនីត្យានុកូលកម្មលើឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សកម្មភាពជួបជុំរបស់គណបក្សនយោបាយនៅមូលដ្ឋាន និងចំនួនជនមានពិការភាពក្នុងបញ្ជីបោះឆ្នោត។



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

គ.ជ.ប បានឆ្លើយសំណួរទាំងនោះម្តងមួយៗ ទៅតាមគោលការណ៍ និងនីតិវិធីនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ហើយបានបញ្ជាក់បន្ថែមជូនថា នៅពេលខាងមុខ គ.ជ.ប មានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ប្រសិនបើគណបក្សនយោបាយ



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

មានបញ្ហា សូមធ្វើការទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដើម្បីជួយសម្របសម្រួលការងារ។ ដោយឡែកជនមានពិការភាពដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០២២ មានចំនួនជាង ៣៤.០០០ (សាមសិបបួនពាន់) នាក់ ក្នុងនោះស្ត្រីមានចំនួនជាង ១៥.០០០ (ដប់ប្រាំពាន់) នាក់។

ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយដែលរៀបចំឡើងដោយ គ.ជ.ប មានតំណាងក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងព័ត៌មាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ វេទិកាសម្ព័ន្ធសង្គមស៊ីវិល ក្រុមប្រឹក្សាសកម្មភាពជនពិការ មន្ត្រីមកពីស្ថានទូតជប៉ុន តំណាងគណបក្សនយោបាយ តំណាងអង្គការសមាគម និងអ្នកសារព័ត៌មាន ប្រមាណ ៧០ នាក់។

# ប្រធាន គ.ជ.ប ទទួលជួបឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ឆ្លើយតបតាមសំណើសុំជួបពិភាក្សាការងាររបស់ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួបសវនាការជាមួយ ឯកឧត្តម **អាណាតូលី បូរ៉ូវីក** (Anatoly BOROVIK) ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងគណៈកម្មាធិការមជ្ឈិមរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី ជាមួយនឹង គ.ជ.ប កម្ពុជា។



**សកម្មភាពក្នុងជំនួបពិភាក្សា**

ឯកឧត្តម **អាណាតូលី បូរ៉ូវីក** បានសម្តែងនូវការអរគុណចំពោះឯកឧត្តមប្រធាន គ.ជ.ប ដែលអនុញ្ញាតឱ្យមានកិច្ចប្រជុំពិភាក្សាទល់មុខគ្នានាពេលនេះ ពីព្រោះដោយសារជំងឺកូវីដ-១៩ បានធ្វើឱ្យជំនួបបែបនេះខកខាន។ ឯកឧត្តមបានសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ដែលជាប្រទេសទី១ នៅអាស៊ីបានចាត់វិធានការជំងឺកូវីដ-១៩ បានជោគជ័យ។ ឯកឧត្តមបន្តថា សហព័ន្ធរុស្ស៊ី អបអរសាទរចំពោះ គ.ជ.ប កម្ពុជា ដែលបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដោយជោគជ័យ ក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈល្អ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។ ប្រជាធិបតេយ្យនៅកម្ពុជាមានលក្ខណៈសមស្របទៅនឹងកត្តាប្រជាសាស្ត្រ ភូមិសាស្ត្រ វប្បធម៌ និងនយោបាយជាក់ស្តែងពិតប្រាកដរបស់កម្ពុជា។ ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់បំផុតរបស់កម្ពុជា ហើយដែលសភាស៊ីវិលនៅសហព័ន្ធរុស្ស៊ីមានការចាប់អារម្មណ៍ និងតាមដាន។ ក្នុងឱកាសនេះ ឯកឧត្តមឯកអគ្គរដ្ឋទូត បានសម្តែងនូវការជឿជាក់ និងជូនពរ ឯកឧត្តម **ប្រាជ្ញ ចន្ទ** សូមឱ្យទទួលបានជោគជ័យក្នុងការរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតនេះ។



**(រូបខាងស្តាំ) ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និង ឯកឧត្តម អាណាតូលី បូរ៉ូវីក ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា**

ឯកឧត្តម **អាណាតូលី បូរ៉ូវីក** បានរំលឹកអំពីអនុស្សាវរណៈដែលភាគីគណៈកម្មាធិការមជ្ឈិមរៀបចំការបោះឆ្នោតនៃសហ-



**សកម្មភាពក្នុងជំនួបពិភាក្សា**



សកម្មភាពក្នុងជំនួបពិភាក្សា

ព័ន្ធរុស្ស៊ី និងភាគី គ.ជ.ប កម្ពុជា បានចុះហត្ថលេខាជាមួយគ្នា កាលពីឆ្នាំ២០១៨ នៅទីក្រុងមូស្គូ ហើយឯកឧត្តមចង់ជំរុញឱ្យមានការអនុវត្តជាក់ស្តែងដើម្បីផ្លាស់ប្តូរអ្នកជំនាញរៀបចំការបោះឆ្នោត ព្រមទាំងមានការសង្កេតមើលការបោះឆ្នោត ការធ្វើសិក្ខាសាលា សន្និសីទបែបវិទ្យាសាស្ត្រ និងកិច្ចប្រជុំតុមូលដែលមានផលប្រយោជន៍ទៅវិញទៅមក ព្រមទាំងមានការចាត់បញ្ជូនតំណាង ដើម្បីពិនិត្យមើលការរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋនៃភាគីនីមួយៗ ជាដើម ។ល។ ឯកឧត្តមបន្តថា កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដែលភាគីសហព័ន្ធរុស្ស៊ី និងភាគីព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា មានឯកសារចំនួន ៧៩ ច្បាប់។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានសម្តែងនូវការស្វាគមន៍ចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញមកជួបពិភាក្សាការងារនៅថ្ងៃនេះ។ ក្នុងឱកាសនេះដែរ ឯកឧត្តមប្រធាន បានមានប្រសាសន៍ពាក់ព័ន្ធនឹងជំនួយឧបត្ថម្ភរបស់អតីតសហភាពសូវៀត និងសហព័ន្ធរុស្ស៊ីជូនដល់ប្រជាជនកម្ពុជាក្នុងគ្រាដ៏សែនលំបាក ដែលបន្សល់ទុកដោយរបបខ្មែរក្រហម។

ពាក់ព័ន្ធនឹងការងារទំនាក់ទំនងរវាងភាគីទាំងពីរ ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានប្រសាសន៍ថា កន្លងមក គ.ជ.ប កម្ពុជា ធ្លាប់បញ្ជូនប្រតិភូរបស់ខ្លួនទៅសង្កេតមើលការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងបានចូលរួមសន្និសីទអន្តរជាតិនៅសហព័ន្ធរុស្ស៊ីផងដែរ។ ចំពោះការបោះឆ្នោតនៅកម្ពុជា ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនភាគីរុស្ស៊ីអំពី៖

- ប្រវត្តិនៃការបោះឆ្នោតនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្នបានចំនួន ១៦ លើក
- ប្រតិទិននៃការបោះឆ្នោត ផែនការមេ និងក្របខណ្ឌច្បាប់
- ការធ្វើទំនើបកម្មនៃដំណើរការរៀបចំការបោះឆ្នោត ដោយការប្រើបច្ចេកវិទ្យាព័ត៌មាន
- ដំណាក់កាលនៃការរៀបចំការបោះឆ្នោតមាន ៤ ដំណាក់កាល
- អំពីនីតិវិធីនៃការបោះឆ្នោត យន្តការនៃការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោត ។ល។

សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** មានប្រសាសន៍ថា គ.ជ.ប នឹងអញ្ជើញស្ថានទូតនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមសង្កេតមើលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ជាភ្ញៀវពិសេស។ ឯកឧត្តមក៏យល់ស្របផងដែរថា ត្រូវជំរុញកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប កម្ពុជា និងគណៈកម្មាធិការមជ្ឈិមរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី ដើម្បីធ្វើឱ្យមានវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការនេះ នៅពេលមានការជួបពិភាក្សាផ្ទាល់រវាងភាគីទាំងពីរ។

ជាថ្មីម្តងទៀត ឯកឧត្តម **អាណាតូលី បូរ៉ូវីក** បានថ្លែងអំណរគុណដល់ឯកឧត្តមប្រធាន គ.ជ.ប ចំពោះការលះបង់ពេលវេលាដ៏មមាញឹក ដើម្បីជួបភាគីប្រតិភូរុស្ស៊ី ហើយសង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរនៅមានជាបន្តបន្ទាប់ទៀត៕



រូបថតអនុស្សាវរីយ៍

# គណបក្សនយោបាយ ចំនួន ១៣ បានដាក់ពាក្យស្នើសុំបង្កើត គណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

ដើម្បីជួយសម្រួលក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបញ្ជីបេក្ខជនរបស់គណបក្សនយោបាយនីមួយៗ គ.ជ.ប បានដាក់ឱ្យប្រើប្រាស់នូវកម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដោយសាមីគណបក្សនយោបាយដែលមានបំណងចង់ប្រើប្រាស់កម្មវិធីនេះ ត្រូវដាក់ពាក្យស្នើសុំបង្កើតគណនីមក គ.ជ.ប។

គិតត្រឹមថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ដែលជាថ្ងៃចុងក្រោយនៃការទទួលពាក្យស្នើសុំ ឃើញថាមានគណបក្សនយោបាយចំនួន ១៣ បានដាក់ពាក្យសុំបង្កើតគណនី និងត្រូវបាន គ.ជ.ប សម្រេចអនុញ្ញាតឱ្យមានសិទ្ធិប្រើប្រាស់។

គណបក្សទាំង ១៣ រួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សឯកភាពជាតិខ្មែរ គណបក្សធម្មាធិបតេយ្យ គណបក្សខ្មែររួបរួមជាតិ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សកម្លាំងប្រជាធិបតេយ្យ គណបក្សបំណងពលរដ្ឋ គណបក្សសញ្ជាតិកម្ពុជា គណបក្សយុវជនកម្ពុជា គណបក្សភ្លើងទៀន គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា និងគណបក្សមហាសាមគ្គីជាតិខ្មែរ។

តាមប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មានរយៈពេល ១៥ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី២៤ ខែមេសា រហូតដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។

តាមរយៈការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ កំហុសឆ្គងដូចជាខុសឈ្មោះ ខុសទិន្នន័យត្រូវបានកាត់បន្ថយ។ ជាមួយគ្នានេះដែរ គណបក្សក៏អាចដឹងជាមុនក្នុងករណីមានបេក្ខជនមិនគ្រប់អាយុ ឬពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬបេក្ខជនឈរឈ្មោះក្នុងបញ្ជីគណបក្សនយោបាយច្រើនជាងមួយ ឬបេក្ខជនឈរឈ្មោះច្រើនមណ្ឌល ដែលជាធម្មតាលក្ខខណ្ឌបែបនេះ នឹងមិនត្រូវបានអនុញ្ញាតឱ្យឈរឈ្មោះជាបេក្ខជនឡើយ ហើយគណបក្សអាចត្រៀមខ្លួន និងរៀបចំបញ្ជីឡើងវិញ ដើម្បីចុះបញ្ជីបានត្រឹមត្រូវ និងទាន់ពេលវេលា៕

---

# គ.ជ.ប រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣" ជូនដល់ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ទាំង ២៥ សមាជិក គធ.ខប ដែលជាប្រធានផ្នែក



**ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប**

សេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ គណបក្សនយោបាយ សមាគម អង្គការមិន-មែនរដ្ឋាភិបាល និងមន្ត្រី គ.ជ.ប សរុបប្រមាណ ១២៩នាក់ នាព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ នៅទីស្តីការ គ.ជ.ប។

វគ្គបណ្តុះបណ្តាលរយៈពេលមួយព្រឹកនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីធានាឱ្យការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប បានថ្លែងក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនេះថា ដើម្បីធានាឱ្យការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រព្រឹត្តទៅស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី និងដោយរលូន ព្រមទាំងមានប្រសិទ្ធភាពខ្ពស់ គឺចាំបាច់ត្រូវមានការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីបទប្បញ្ញត្តិនៃច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងបច្ចេកទេសក្នុងការរៀបចំបញ្ជីបេក្ខជន និងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមកម្មវិធីកុំព្យូទ័រ និងដោយដៃ។



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

ឯកឧត្តមបានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលលើកនេះមានលក្ខណៈខុសប្លែកពីវគ្គបណ្តុះបណ្តាលមុនៗ ដោយនាពេលនេះ យើងធ្វើការបណ្តុះបណ្តាលទាំងនីតិវិធីនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ រួមទាំងមានការបង្ហាញពីរបៀបអនុវត្តកម្មវិធី ជាពិសេសគឺការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការរៀបចំបញ្ជីបេក្ខជន ដើម្បីជាជំនួយដល់គណបក្សនយោបាយ ក៏ដូចជាមន្ត្រីបោះឆ្នោត។



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់ទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីបន្ថែមទៀត ដើម្បីយកទៅអនុវត្តការងារពាក់ព័ន្ធនឹងការរៀបចំការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ និងមានភាពត្រឹមត្រូវ។

សូមបញ្ជាក់ជូនថា តាមប្រតិទិនរបស់ គ.ជ.ប ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ចាប់ផ្តើមពីថ្ងៃទី២៤ ខែមេសា រហូតដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ គឺមានរយៈពេល ១៥ថ្ងៃ៕

# ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស សម្រាប់បេក្ខជនឈរឈ្មោះ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទ រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។

ក្នុងករណីមានបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយណាស្ថិតនៅក្នុងស្ថានភាពដូចបានរៀបរាប់ខាងលើ បេក្ខជននោះត្រូវ៖

- ភ្ជាប់ច្បាប់ថតចម្លងលិខិតស្នើសុំអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាព ដោយមានចុះហត្ថលេខារបស់ថ្នាក់លើមួយថ្នាក់យ៉ាងតិច ដែលខ្លួននៅក្រោមឱវាទ ភ្ជាប់មកជាមួយសំណុំពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ
- ធ្វើកិច្ចសន្យាតាមទម្រង់ដែលផ្តល់ជូនដោយ គ.ជ.ប ដើម្បីធានាថា នឹងប្រគល់លិខិតអនុញ្ញាតច្បាប់ឈប់ពិសេសដែលប្រធានក្រសួង ស្ថាប័ន ឬអង្គភាពសម្រេចជាផ្លូវការមក គ.ជ.ប (ការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល) ឱ្យបានយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត (កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ជាកំហិត)។

សូមជម្រាបជូនថា តាមប្រតិទិនរបស់ គ.ជ.ប ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គឺមានរយៈពេល ១៥ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២៤ ខែមេសា រហូតដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣៕

# ការងារចាំបាច់ចំពោះមុខ គឺការធានាឱ្យបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ ជាពិសេសក្នុងដំណើរការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានមានប្រសាសន៍ថា ការងារចាំបាច់ចំពោះមុខ គឺការធានាឱ្យបាននូវស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេសក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ខាងមុខនេះ។ ការលើកឡើងបែបនេះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរួម ស្តីពីសកម្មភាព និងការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងយុទ្ធនា-



សកម្មភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរួម




(រូបខាងស្តាំ) ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ការការពារដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលបានធ្វើកាលពីថ្ងៃទី៦ ខែមេសា កន្លងទៅនេះ។

កិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរួមនេះ ប្រព្រឹត្តទៅនៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) និងឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប។

ឯកឧត្តមប្រធាន គ.ជ.ប ក៏បានថ្លែងនូវអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដែលបានផ្តល់កិច្ចសហការដល់ គ.ជ.ប និងការដាក់ចេញនូវសេចក្តីណែនាំរួមលេខ ០១ សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ក្នុងគោលបំណងធានាឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខល្អប្រសើរ ធានាបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពសង្គម គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា។

ឯកឧត្តមប្រធានបានបញ្ជាក់ទៀតថា គ.ជ.ប មានការជឿជាក់ប្រកបដោយសុទិដ្ឋិនិយមថា លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ នឹងបង្កើនកិច្ចសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទក្រោមការដឹកនាំដោយផ្ទាល់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ដែលមាន សម្តេចក្រឡាហោម **ស ខេង** ជាប្រធាន ដើម្បីបង្កើតបរិយាកាសមួយដ៏ប្រសើរមុនពេលបោះឆ្នោត ក្នុងពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតសំដៅធ្វើឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា៕



សកម្មភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរួម

# សំណួរ-ចម្លើយ ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

**សំណួរ: តើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំការបោះឆ្នោត ប៉ុន្មានលើករួចមកហើយ?**

ចម្លើយ: គ.ជ.ប បានរៀបចំការបោះឆ្នោត ចំនួន ១៦ លើក ក្នុងនោះ៖

- បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៥ លើក
- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ៥ លើក

- បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ៣ លើក
- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ៣ លើក។

**សំណួរ: តើ គ.ជ.ប បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចំនួនប៉ុន្មានលើក? នៅឆ្នាំណាខ្លះ?**

ចម្លើយ: គ.ជ.ប បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របាន ៥ លើក លើកទី១ ឆ្នាំ១៩៩៨ លើកទី២ ឆ្នាំ២០០៣ លើកទី៣ ឆ្នាំ២០០៨ លើកទី៤ ឆ្នាំ២០១៣ និងលើកទី៥ ឆ្នាំ២០១៨។

**សំណួរ: តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅពេលណា?**

ចម្លើយ: ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣។

**សំណួរ: តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានមណ្ឌលបោះឆ្នោត ចំនួនប៉ុន្មាន? និងមានអាសនៈចំនួនប៉ុន្មាន?**

ចម្លើយ: ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានមណ្ឌលបោះឆ្នោត ចំនួន ២៥ និងមានអាសនៈចំនួន ១២៥។

**សំណួរ: តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានអ្នកបោះឆ្នោតចំនួនប៉ុន្មាននាក់? និងមានការិយាល័យបោះឆ្នោត ចំនួនប៉ុន្មាន?**

ចម្លើយ: ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានអ្នកបោះឆ្នោត ចំនួន ៩.៧១០.៦៤៥ នាក់ ស្រី ៥.១៦១.៩០៩ នាក់ និងមានការិយាល័យបោះឆ្នោតចំនួន ២៣.៧៨៩ ការិយាល័យ។

**សំណួរ: តើការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត មានប៉ុន្មានលើក? នៅពេលណា? និងទីកន្លែងណា?**

ចម្លើយ: ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត មានចំនួន ១លើក នៅ ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត បិទផ្សាយនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប)។

**សំណួរ: ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តើប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?**

ចម្លើយ: ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា
- មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

**សំណួរ: តើនរណាខ្លះដែលគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ?**

ចម្លើយ: អ្នកគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានដូចខាងក្រោម៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច
- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជី

បោះឆ្នោតដោយ គ.ជ.ប
- សមាជិក គ.ជ.ប និងគណៈកម្មការរៀបចំការបោះ-ឆ្នោត គ្រប់លំដាប់ថ្នាក់
- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

**សំណួរៈ បើចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ តើត្រូវធ្វើដូចម្តេច?**

ចម្លើយៈ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

**សំណួរៈ តើបេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយបានចំនួនប៉ុន្មាន?**

ចម្លើយៈ បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជន នៃគណបក្សនយោបាយបានតែមួយប៉ុណ្ណោះ។

**សំណួរៈ តើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនមានទម្រង់លេខប៉ុន្មាន?**

ចម្លើយៈ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះ-ឆ្នោត និងបញ្ជីបេក្ខជនមានទម្រង់បែបបទ លេខ ១០០៨ (ទ.១០០៨)។

**សំណួរៈ តើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន (ទ.១០០៨) ត្រូវភ្ជាប់មកជាមួយនូវអ្វីខ្លះ?**

ចម្លើយៈ ពេលយកពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនទៅដាក់នៅ គ.ជ.ប ត្រូវភ្ជាប់ជាមួយនូវៈ
- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃចំនួន ១ច្បាប់
- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ
- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោ-បាយ
- បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុង ចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ
- ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានបេក្ខជនគ្រប់តាមចំនួនអាសនៈ និងតាមគំរូដែល គ.ជ.ប ផ្តល់ជូន។ ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈ ១ (មួយ) ឬ ២ (ពីរ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិច ៣ (បី) រូប
- សេចក្តីប្រកាសអំពីគណនីធនាគារដែលគណបក្សនយោបាយ បានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា
- លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ
- សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះ-ឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ត.រ ប.ន.ត.រ របស់ គ.ជ.ប និងក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ
- បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មា-ធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ
- បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយអគ្គនាយក-ដ្ឋានរតនាគារជាតិ។

**សំណួរៈ តើការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះមានរយៈពេលប៉ុន្មានថ្ងៃ?**

ចម្លើយៈ ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ១៥ថ្ងៃ

ចាប់ពីថ្ងៃទី២៤ ខែមេសា ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ គឺរៀងរាល់ថ្ងៃ ពេលព្រឹក ចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀល ចាប់ពីម៉ោង ២:០០នាទី ដល់ម៉ោង ៥:៣០នាទី។

**សំណួរ: បន្ទាប់ពីបានទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន តើ គ.ជ.ប ត្រូវធ្វើអ្វីខ្លះ?**

ចម្លើយ: បន្ទាប់ពីបានទទួលពាក្យ គ.ជ.ប ត្រូវធ្វើការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

**សំណួរ: តើអ្វីទៅដែលហៅថាការឃោសនាបោះឆ្នោត?**

ចម្លើយ: ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

**សំណួរ: តើការឃោសនារបស់គណបក្សនយោបាយមានបំណងអ្វី?**

ចម្លើយ: ការឃោសនារបស់គណបក្សនយោបាយ គឺមានទិសដៅសម្រាប់ធ្វើការផ្សព្វផ្សាយអំពីកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត។

**សំណួរ: តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកជាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ?**

ចម្លើយ: សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយមានជាអាទិ៍៖

- ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន
- ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬ ដោយយានជំនិះគ្រប់ប្រភេទ
- ការជួបជុំ ឬការឃោសនាតាមផ្ទះ
- ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន
- ការផ្សព្វផ្សាយតាមលេកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែតវីដេអូ ឬ VCD ឬ DVD ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ
- សកម្មភាពបិទផ្សាយនូវបដា ពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា
- សកម្មភាពចែកចាយខិត្តបណ្ណគណបក្សនយោបាយ
- សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិត ដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត
- សកម្មភាពលើកបដានៅទីសាធារណៈ
- ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា
- ការរៀបចំកម្មវិធីប្រកួតកីឡា ឬការលេងភ្លេងឃោសនាបោះឆ្នោត។

**សំណួរ: តើការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានរយៈពេលប៉ុន្មានថ្ងៃ?**

ចម្លើយ: ការឃោសនាបោះឆ្នោតត្រូវបើករយៈពេល ២២ (ម្ភៃពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត។

**សំណួរ: គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ចាប់ផ្ដើមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?**

ចម្លើយ: គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវ៖

- ចាប់ផ្ដើមពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់ ) យប់
- ឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេងត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ)

រសៀល។

**សំណួរ: តើការឃោសនាបោះឆ្នោតត្រូវបញ្ឈប់នៅពេលណា?**

ចម្លើយ: គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះនឹងត្រូវទទួលការពិន័យតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

**សំណួរ: ការលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយហាមនៅទីកន្លែងណាខ្លះ?**

ចម្លើយ: ការលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនាសម្រាប់គណបក្សនយោបាយ មិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

**សំណួរ: តើគណបក្សនយោបាយអាចលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋបានដែរឬទេ?**

ចម្លើយ: គណបក្សនយោបាយអាចលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនារូបសញ្ញាឃោសនាពាក្យស្លោក ខិត្តបណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋបាន ប្រសិនបើមានការយល់ព្រមពីម្ចាស់លំនៅឋាន។

**សំណួរ: តើការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅក្នុងរាជធានីខេត្តក្នុងអំឡុងពេលឃោសនាបានប៉ុន្មានដង?**

ចម្លើយ: ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ៤ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

**សំណួរ: តើការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទត្រូវបានកំណត់ទម្រង់ និងទំហំបែបណា?**

ចម្លើយ: ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំដូចខាងក្រោម៖

- មានការរៀបចំជាក្បួន មានបិទបដា ឬនិងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង
- មានអ្នកចូលរួមចាប់ពី ២០នាក់ ឡើងទៅ ដោយប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោតមានដូចខាងក្រោម៖
  - រថយន្តចាប់ពី ២ គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ចាប់ពី ១០ គ្រឿងឡើងទៅ
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ គ្រឿងឡើងទៅ
  - ជលយានគ្រប់ប្រភេទចាប់ពី ៥ គ្រឿងឡើងទៅ។

**សំណួរ: គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត តើត្រូវជូនដំណឹងទៅនរណា? ហើយការជូនដំណឹងនេះត្រូវបញ្ជាក់អំពីអ្វីខ្លះ?**

ចម្លើយ: គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគធ.ឧប យ៉ាងហោចណាស់ឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា។ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ
- កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន
- ទីតាំងប្រមូលផ្តុំ និងតម្រាយផ្លូវដែលត្រូវហែក្បួន និងទីតាំងរំសាយ
- ចំនួនអ្នកចូលរួម
- ចំនួនយានជំនិះតាមប្រភេទនីមួយៗ។

**សំណួរ: ក្នុងដំណើរការបោះឆ្នោត តើមេភូមិ និងជំនួយការមេភូមិ ត្រូវធ្វើឱ្យបាននូវសកម្មភាពអ្វីខ្លះ?**

ចម្លើយ: ក្នុងដំណើរការបោះឆ្នោត មេភូមិ និងជំនួយការមេភូមិ ត្រូវធ្វើឱ្យបាននូវសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- ផ្តល់សេវា និងព័ត៌មានដូចៗគ្នាជូនដល់អ្នកភូមិទាំងអស់ដោយមិនប្រកាន់និន្នាការនយោបាយដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា
- ធានាថាការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗដទៃទៀតត្រូវបានអនុវត្តដោយយុត្តិធម៌ ដោយស្មើភាព និងអស់ពីកម្លាំងចិត្តដល់អ្នកភូមិគ្រប់ៗរូប និងដោយឥតគិតថ្លៃ
- ត្រូវប្រកាន់ខ្ជាប់ឥរិយាបថ អព្យាក្រឹត ឥតលម្អៀង នៅក្នុងការបំពេញការងារទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត
- ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូបឱ្យបានស្មើគ្នាផ្តល់កិច្ចសហការជាមួយនឹង គឃ.សប គជ.ខប និង គ.ជ.ប ទាក់ទងនឹងការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានអំពីការបោះឆ្នោត ការចែកខិត្តបណ្ណ សៀវភៅព័ត៌មាន ឬបណ្ណប្រកាសផ្សេងៗដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

**សំណួរ: តើគណៈកម្មការសម្របសម្រួល ដែលបង្កើតឡើងដោយ គ.ជ.ប មានតួនាទី និងភារកិច្ចអ្វីខ្លះ?**

ចម្លើយ: គណៈកម្មការសម្របសម្រួល មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យ និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងករណីមានការស្នើពីសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាងដទៃទៀត សម្របសម្រួលកម្មវិធីស្មើភាព ឬ/និងសមធម៌ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត
- សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ក្នុងពេលឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ
- សម្របសម្រួលជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព និងសមធម៌សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

**សំណួរ: តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមានសមាសភាព ប៉ុន្មានរូប? ចូររៀបរាប់?**

ចម្លើយ: គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមានសមាសភាព ៥ ឬ ៧រូប៖

- ប្រធាន ១រូប ទទួលបន្ទុកលើការងាររួម និងការងារហិរញ្ញវត្ថុ
- អនុប្រធាន ១រូប ជួយធ្វើការប្រធាន និងទទួលបន្ទុកការងារប្រតិបត្តិការ និងបច្ចេកទេស
- សមាជិក ទទួលបន្ទុកការងាររដ្ឋបាល ១រូប
- សមាជិក ទទួលបន្ទុកការងារសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១រូប
- សមាជិក ទទួលបន្ទុកការងារអប់រំ ព័ត៌មាន និងទំនាក់-

ទំនងសាធារណៈ ១រូប ទៅ ៣រូប។

**សំណួរ: តើគណៈកម្មការការិយាល័យបោះឆ្នោតមានសមាសភាពប៉ុន្មានរូប? ចូររៀបរាប់?**

ចម្លើយ: គណៈកម្មការការិយាល័យបោះឆ្នោតមានសមាសភាព ៦រូប គឺ៖

- ប្រធាន ១រូប ទទួលខុសត្រូវរួម
- អនុប្រធាន ១រូប
- លេខាធិការ ១រូប
- សមាជិកទី១ ១រូប
- សមាជិកទី២ ១រូប
- សមាជិកទី៣ ១រូប។

**សំណួរ: តើការបោះឆ្នោតចាប់ផ្តើមនៅម៉ោងប៉ុន្មាន?និងបញ្ចប់នៅម៉ោងប៉ុន្មាន?**

ចម្លើយ: ការបោះឆ្នោតចាប់ផ្តើមនៅម៉ោង ៧:០០នាទីព្រឹក និងបញ្ចប់នៅម៉ោង ៣:០០នាទីរសៀល។

**សំណួរ: តើការិយាល័យបោះឆ្នោតមួយមានអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតប៉ុន្មាននាក់?**

ចម្លើយ: ការិយាល័យបោះឆ្នោតមួយមានអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹម ៧៥០ (ប្រាំពីររយហាសិប) នាក់។

**សំណួរ: តើសម្ភារឯកសារសំខាន់ៗដែលគណៈកម្មការការិយាល័យបោះឆ្នោត មិនបានទទួលហើយរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត មានប៉ុន្មានមុខ?**

ចម្លើយ: សម្ភារឯកសារសំខាន់ៗ ដែលគណៈកម្មការការិយាល័យបោះឆ្នោតមិនបានទទួលហើយអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោតមាន ៥មុខ គឺ៖

- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ
- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់
- ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត
- ហិបឆ្នោត និងសោឃ្លុំមានលេខ
- ទឹកខ្មៅលុបមិនជ្រះ។

**សំណួរ: តើនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិអ្វីខ្លះ?**

ចម្លើយ: នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិដូចខាងក្រោម៖

- សង្កេតមើលគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- លើកការជំទាស់ ឬ/និងការតវ៉ាដោយផ្ទាល់មាត់ទៅប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ចុះហត្ថលេខាលើកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

**សំណួរ: តើអ្នកសង្កេតការណ៍មានសិទ្ធិអ្វីខ្លះ?**

ចម្លើយ: អ្នកសង្កេតការណ៍ មានសិទ្ធិដូចខាងក្រោម៖

- ចេញ-ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្កការរំខាន
- ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ
- ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួនដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

**សំណួរ: តើការិយាល័យបោះឆ្នោតអាចបិទនៅមុនម៉ោង ៣រសៀលបានដែរឬទេ?**

ចម្លើយ: ការិយាល័យបោះឆ្នោតទូទៅបិទនៅម៉ោង ៣:០០នាទី

រសៀល ប៉ុន្តែក្នុងករណីប្រជាពលរដ្ឋបានទៅបោះឆ្នោតគ្រប់ចំនួនតាមឈ្មោះក្នុងបញ្ជីបោះឆ្នោត ការិយាល័យបោះឆ្នោតនោះអាចបិទនៅមុនម៉ោង ៣:០០នាទីរសៀលបាន។

**សំណួរ: ប្រសិនបើដល់ម៉ោង ៣:០០នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោត ស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតទៀត តើគណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើដូចម្តេចខ្លះ?**

ចម្លើយ: ប្រសិនបើដល់ម៉ោង ៣:០០នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតទៀតអ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោតដោយត្រូវ៖

- ឱ្យសមាជិកទី២ ប្រកាសប្រាប់អ្នកបោះឆ្នោតឈរតម្រង់ជួររួចប្រមូល អ.ខ ឬ ឯ.អ ដោយចាប់ផ្តើមពីអ្នកដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់រួច ប្រគល់ទៅឱ្យសមាជិកទី៣ នៅត្រង់មាត់ទ្វារ
- សមាជិកទី៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោតតាមលំដាប់លំដោយ រហូតដល់អ្នកបោះឆ្នោតបានបោះឆ្នោតអស់។

**សំណួរ: តើទម្រង់លេខ ១១០១ និងទម្រង់លេខ ១១០២ ប្រើសម្រាប់ធ្វើអ្វី?**

ចម្លើយ: ទម្រង់លេខ១១០១ប្រើសម្រាប់ធ្វើកំណត់ហេតុនៃការបោះឆ្នោត និងទម្រង់លេខ ១១០២ ប្រើសម្រាប់ធ្វើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

**សំណួរ: តើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បិទផ្សាយនៅកន្លែងណាខ្លះ?**

ចម្លើយ: កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ត្រូវបិទផ្សាយនៅការិយាល័យបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

**សំណួរ: តើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ (ទ.១១០៣) បិទផ្សាយនៅកន្លែងណា? នៅពេលណា?**

ចម្លើយ: កំណត់ហេតុ ទ.១១០៣ បិទផ្សាយនៅទីស្នាក់ការ គឃ.សប បន្ទាប់ពី គឃ.សប បានត្រួតពិនិត្យការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់រួចរាល់។

**សំណួរ: តើការត្រួតពិនិត្យការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹក-ឆ្នោតនានាក្នុងឃុំ សង្កាត់ មានរយៈពេលប៉ុន្មានថ្ងៃ?**

ចម្លើយ: ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនានាក្នុងឃុំ សង្កាត់បញ្ចូលគ្នាឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើទៅបាន និងមិនត្រូវឱ្យហួសរយៈពេល ២ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតឡើយ។

**សំណួរ: តើការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ធ្វើនៅពេលណា?**

ចម្លើយ: ការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោត-ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅចន្លោះពីថ្ងៃទី៩ ខែសីហា ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣។

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីមែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News